№-44
30-11-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

ឆ្នាំទី ៥ លេខ ៤៤ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

មាតិកា

***

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៤.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥៤ តែងតាំងឯកឧត្តម ទី ឈិន ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ២៥១៩

២៤.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥៥ តែងតាំងឯកឧត្តម ឡុង បូរ៉ា ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ២៥២០

២៤.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥៦ តែងតាំងឯកឧត្តម ផៃ ស៊ីផាន ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ២៥២១

២៤.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥៧ តែងតាំងឯកឧត្តម តាក ស៊ុនអ៊ី ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ ២៥២២

២៦.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥៨ តែងតាំងឯកឧត្តម អ៊ិន សារូ ជាអនុរដ្ឋលេខាធិការ អមទីស្តីការគណៈរដ្ឋមន្ត្រី ២៥២៣

២៦.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៥៩ តែងតាំងលោក ជិតាវ ចាយ ដារាវិចិត្រ ជាអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ២៥២៤

២៧.១១.១៩៩៧ -ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦០ តែងតាំងលោក អាន សំអុល ជាអ្នកឧកញ៉ា ២៥២៥

២៨.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦២ តែងតាំងឯកឧត្តម ឧត្តមសេនិយ៍ត្រី ណា សាំងហៀង ជាទីប្រឹក្សាឯកឧត្តម អ៊ឹង ហួត ២៥២៦

២៨.១១.១៩៩៧ –ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៦៣ តែងតាំងឯកឧត្តម អ្លុង ពិន លីណារី ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម អ៊ឹង ហួត ២៥២៧

II-រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

២៨.១១.១៩៩៧ _អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្ដីពីការផ្ទេរឥណទាន ២៥២៨
២៦.១១.១៩៩៧ _អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៥៣០
២៦.១១.១៩៩៧ _អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៥៣១
២៦.១១.១៩៩៧ _អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៥៣២
២៨.១១.១៩៩៧ _អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៥៣៣
២៨.១១.១៩៩៧ _អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៥៣៤

២_សេចក្ដីសំរេច

២៦.១១.១៩៩៧ _សេចក្ដីសំរេចលេខ ៤៩ សសរ ស្ដីពីការផ្ទេរសិទ្ធិ ២៥៣៥
២៨.១១.១៩៩៧ _សេចក្ដីសំរេចលេខ ៥០ សសរ ស្ដីពីការជួលដីបឹងកំផ្លោកក្នុងបរិវេណ
រាជាយស្វ័យយានកម្ពុជាជាប់មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ២៥៣៧

III-ការងារបណ្ដាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

២៨.១១.១៩៩៧ _ប្រកាសលេខ ៣៣៤ ពណ.បល.ប្រក ស្ដីពីការរៀបចំ និងការ
ប្រព្រឹត្តិទៅរបស់នាយកដ្ឋានរដ្ឋបាល ២៥៣៩
២៨.១១.១៩៩៧ _ប្រកាសលេខ ៣៣៥ ពណ.បល.ប្រក ស្ដីពីការរៀបចំ និងការ
ប្រព្រឹត្តិទៅរបស់នាយកដ្ឋានបុគ្គលិក ២៥៤៣
២៨.១១.១៩៩៧ _ប្រកាសលេខ ៣៣៦ ពណ.បល.ប្រក ស្ដីពីការរៀបចំ និងការ
ប្រព្រឹត្តិទៅរបស់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ២៥៤៦
២៨.១១.១៩៩៧ _ប្រកាសលេខ ៣៣៧ ពណ.បល.ប្រក ស្ដីពីការរៀបចំ និងការ
ប្រព្រឹត្តិ ទៅរបស់នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ២៥៤៩

២៨.១១.១៩៩៧ –ប្រកាសលេខ ៣៣៨ ពណ.បល.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ២៥៥៤
២៨.១១.១៩៩៧ –ប្រកាសលេខ ៣៣៩ ពណ.បល.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋាននីតិកម្ម ២៥៥៨
២៨.១១.១៩៩៧ –ប្រកាសលេខ ៣៤០ ពណ.បល.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ២៥៦០
២៨.១១.១៩៩៧ –ប្រកាសលេខ ៣៤១ ពណ.បល.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ២៥៦៣
២៨.១១.១៩៩៧ –ប្រកាសលេខ ៣៤២ ពណ.បល.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ២៥៦៦
២៨.១១.១៩៩៧ –ប្រកាសលេខ ៣៤៣ ពណ.បល.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិ ទៅរបស់នាយកដ្ឋានជំរុញការនាំចេញ ២៥៦៩

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

២៦.១១.១៩៩៧ –ប្រកាសលេខ ៧៩១ អយក.ប្រក ស្តីពីការអនុញ្ញាតអោយបើកសាលាឯកជនខ្មែរ-វៀតណាម តឹង តៀន ២៥៧២

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត ១១/៩៧ /២៥៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .– តែងតាំងឯកឧត្តម **ទី ឈិន** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២ .– នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រី ទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត ១១/៩៧/២៥៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុង កម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម **ឡុង ម៉ូរ៉ា** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២ .- នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត ១១/៩៧/២៥៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

– បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .– តែងតាំងឯកឧត្តម **ផៃ ស៊ីផាន** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ .– នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត ១១/៩៧/២៥៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .– តែងតាំងឯកឧត្តម **តាក ស៊ុនអ៊ី** ជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ .– នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត ១១/៩៧/២៥៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជបរិវង្ស ឧត្តមសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .– តែងតាំងឯកឧត្តម **រិុន សាវូ ជាអនុរដ្ឋលេខាធិការ** អមទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ .– នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ .– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត ១១/៩៧/២៥៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .— តែងតាំងលោកជំទាវ **ចាយ ដារាវិចិត្រ** ជាអនុរដ្ឋលេខាធិការ ក្រសួងអប់រំ ។

មាត្រា ២ .— នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសម្រេច ។

មាត្រា ៣ .— ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត ១១/៩៧/២៦០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក អាន សំអុល

ជា

អ្នកឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * * *

ព្រះរាជក្រឹត្យ ជស/រកត ១១/៩៧/២៦២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ .– តែងតាំងឯកឧត្តមឧត្តមសេនីយ៍ត្រី **ឈិា សាំងហៀង** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **អ៊ុង ហួត** នាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកកិច្ចការសន្តិសុខ ដោយមានឋានៈស្មើនឹង **រដ្ឋលេខាធិការ** ។

មាត្រា ២ .– នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

\.....

ព្រះរាជក្រឹត្យ ជស/រកត /១១/៩៧/២៦៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

–យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងឯកឧត្តម **អួង ប៊ុនលីណារី** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **អ៊ឹង ហួត** នាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកទំនាក់ទំនងកិច្ចការសាលាក្រុងភ្នំពេញ ដោយមានឋានៈ ស្មើនឹង **អនុរដ្ឋលេខាធិការ** ។

មាត្រា២.–នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

II-រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

អនុក្រឹត្យ លេខ ៧៧ អនក្រ_បក

ស្ដីពីការផ្ទេរឥណទាន

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ។
- បានឃើញច្បាប់ ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាល ស្ដីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

– បានឃើញប្រកាសលេខ ០១ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែមករា ឆ្នាំ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីចំណាត់ថ្នាក់ចំណូល និងចំណាយថវិកាតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៤ និងប្រកាសស្ដីពីការកែប្រែ និងបំពេញបន្ថែមជាបន្តបន្ទាប់មាន : លេខ ០២២ ប្រ.សហវ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ១៩៩៤ លេខ ០០៣ ប្រ.សហវ ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ១៩៩៥ លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ១៩៩៥, លេខ ៣៣៦ ប្រក.សហវ.ថ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ១៩៩៥ លេខ ០៧១ ប្រក.សហវ.ថ ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ១៩៩៦ និងលេខ ៨០១ សហវ.ថ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ១៩៩៦

– តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា១.– ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) ចំនួន ៧២០ លានរៀល (ប្រាំពីររយម្ភៃលានរៀលគត់) មកជំពូក ១០ (បៀវត្ស និងប្រាក់បំណាច់) ក្នុងវង្វង់ថវិការបស់ក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា២.– ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ ដើម្បីផ្ដល់ជូនក្រសួងសុខាភិបាល សំរាប់បើកប្រាក់ម៉ោងបន្ថែមជូនសាស្ត្រាចារ្យ បង្រៀននៅមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ និងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រក្នុងឆ្នាំ ១៩៩៧ ។

មាត្រា៣ .– ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

អនុក្រឹត្យលេខ ២២៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សម្រេច

មាត្រា១.- ត្រូវបានប្រគល់មេដាយ **សំរិទ្ធ** ស្ថាបនាជាតិជូនលោក **យូ សាន្ត** ប្រធានក្រុមហ៊ុនស៊ីនអ៊ីលីមីធិត ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ៣.០០០ ដុល្លារអាមេរិកសំរាប់ជួយកសាងវិស័យអប់រំនៅក្នុងរាជធានីភ្នំពេញ ។

មាត្រា២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ុង ហួត ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ២២៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

* * *

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

–តាមសំណើរបស់ឯកឧត្តម **ឯក សំអុល** តំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង

សម្រេច

មាត្រា ១.–ត្រូវបានប្រគល់មេដាយ **សេរីវឌ្ឍ** ស្ថាបនាជាតិ ជូនសប្បុរសជនខ្មែរ ០២ រូប នៅស្រុកស្តុនរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអា[illegible] ដែលបានផ្តល់អំណោយដល់ប្រជារាស្ត្រ ក្នុងស្រុកព្រៃវែង ខេត្តព្រៃវែង ក្នុងនោះ មានអង្ករ ២០តោន និងអណ្តូងទឹក ៥១ អណ្តូង ចំណាយអស់ទឹកប្រាក់ចំនួន ៩.១០០ ដុល្លារអាមេរិក ដូចមាននាមខាងក្រោម ÷

១–លោក **ឡៅ ចាយ**

២–អ្នកស្រី **ឆាំង ប៊ុន**

មាត្រា ២.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

* * * *

អនុក្រឹត្យ លេខ ២២៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

* * * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា១.– ត្រូវបានប្រគល់មេដាយ **មាស** ស្ថាបនាជាតិ ជូនស្ថានឯកអគ្គរាជទូតជប៉ុន [illegible]ព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់អំណោយតាងនាមរាជរដ្ឋាភិបាលជប៉ុ[illegible] នូវអាគារសិក្សា ចំនួន ៣ខ្នង មាន ១២បន្ទប់ ដល់សាលាបឋមសិក្សា ស្វាយព្រៃ ក្នុងឃុំ

សណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម មានតម្លៃជាទឹកប្រាក់ ៦៥.២០០ ដុល្លារអាមេរិក ។

មាត្រា២.– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * *

អនុក្រឹត្យ លេខ ២២៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

–ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា១._តែងតាំងលោកឧត្តមសេនីយត្រី **ចាប តន្ត្រី** ជាសមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រីទី២ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * * *

អនុក្រឹត្យ លេខ ២២៩ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

* * * *

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-ពិនិត្យសំណូមពរការងារ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

មាត្រា ១._តែងតាំងលោកឧត្តមសេនីយ៍ត្រី **ម៉ៅ សុផាន់** ជា**នាយកខុទ្ទកាល័យ**សម្តេចនាយករដ្ឋមន្ត្រីទី ២ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២._សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * * *

២_សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ៤៩ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

រាជរដ្ឋាភិបាល

....

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ខាំ ចាន់គូ** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅពិនិត្យជម្ងឺនៅទីក្រុង បាងកក ប្រទេសថៃឡង់ដ៍ ចាប់ពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ រហូតដល់ពេល ឯកឧត្តម **ចម ប្រសិទ្ធ** វិលត្រឡប់មកវិញ ។

ប្រការ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **ខាំ ចាន់គូ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

* * * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥០ សសរ.

ស្តីពីការជួលដីបឹងកំផ្លោកក្នុងបរិវេណរាជាយស្វ័យយានកម្ពុជា ជាប់មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- យោងលិខិតចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៧ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន ស្តីពីករណីស្នើសុំជួលដីបឹងកំផ្លោកក្នុងបរិវេណរាជាយស្វ័យយានកម្ពុជា ជាប់មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ របស់ក្រុមហ៊ុនហាស្សាន់ខេមបូឌា ឌីវ៉ឺឡុបមិន លីមីធិដ
- យោងតាមការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ និងការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : ត្រូវបានយល់ព្រមអនុញ្ញាតអោយក្រសួងសាធារណការនិងដឹកជញ្ជូន ជួលដីបឹងកំផ្លោក ស្ថិតក្នុងបរិវេណរាជាយស្ម័យយានកម្ពុជា ជាប់មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ១០ហិកតា ទៅអោយក្រុមហ៊ុន ហាស្សាន់ ខេមបូឌា ឌីវី ឡុបមិន លីមីធិត ដើម្បីសាងសង់សំណង់ខ្នាតអន្តរជាតិ សំរាប់ធ្វើអាជីវកម្មរយៈពេល ៧០ឆ្នាំ ។

ប្រការ ២ : ក្រុមហ៊ុន ហាស្សាន់ ខេមបូឌា ឌីវី ឡុបមិន លីមីធិត ត្រូវធ្វើការពិភាក្សាលំអិតបន្ថែម អំពីការបង់ថ្លៃឈ្នួលដីតាមឆ្នាំនីមួយៗ ជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋានគិតគូរដូចតទៅ ÷

រយៈពេលជួល៧០ឆ្នាំ	ថ្លៃឈ្នួលដីក្នុង១ម៉ែត្រការ៉េក្នុង១ឆ្នាំ	ថ្លៃឈ្នួលដីរយៈពេល ៧០
ឆ្នាំទី១ដល់ឆ្នាំទី១០	១,៥ ដុល្លារអាមេរិក	១.៥០០.០០០ ដុល្លារអាមេរិក
១១_២០	២ ដុល្លារអាមេរិក	២.០០០.០០០ ដុល្លារអាមេរិក
២១_៣០	២ ដុល្លារអាមេរិក +៥%	២.១០០.០០០ ដុល្លារអាមេរិក
៣១_៤០	២ ដុល្លារអាមេរិក +៥%	២.២០០.០០០ ដុល្លារអាមេរិក
៤១_៥០	២ ដុល្លារអាមេរិក +៥%	២.៣០០.០០០ ដុល្លារអាមេរិក
៥១_៦០	២ ដុល្លារអាមេរិក +៥%	២.៤០០..០០០ ដុល្លារអាមេរិក
៦១_៧០	២ ដុល្លារអាមេរិក +៥%	២.៥០០.០០០ ដុល្លារអាមេរិក

ប្រការ ៣ : ក្រសួងសាធារណការនិងដឹកជញ្ជូន រួមជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិភាក្សា និងចុះហត្ថលេខាជាមួយក្រុមហ៊ុន ហាស្សាន់ ខេមបូឌា ឌីវី ឡុបមិន លីមីធិត លើកិច្ចសន្យាលំអិត ស្តីពីការជួលដីដែលចែងក្នុងប្រការ ១ អោយបានឆាប់ ដើម្បីបង្កើតប្រភពបង់ចំណូលមូលថវិការដ្ឋ រួមចំណែកកែលំអសោភ័ណភាពរាជធានីភ្នំពេញ និងដោះស្រាយការងារជូនប្រជាពលរដ្ឋ ។

ប្រការ ៤ : ការវិនិយោគសាងសង់ សំណង់ខ្នាតអន្តរជាតិ លើដីជួលនេះ ក្រុមហ៊ុន ហាស្សាន់ ខេមបូឌា ឌីវី ឡុបមិន លីមីធិត ត្រូវបំពេញបែបបទ និងអនុវត្តនីតិវិធី អោយស្របតាម ច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

ប្រការ ៥ : លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៦២៩ សជណ. ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៧ ស្តីពីករណីសុំផ្តូលដីបឹងកំផ្លោក ក្នុងបរិវេណរាជាយស្ម័យយានកម្ពុជា ភ្នំពេញ និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និងក្រុមហ៊ុន ហាស្សាន់ ខេមបូឌា ឌីវឡុបមិន លីមីធិត ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

* * * *

ការងារបណ្តាក្រសួង

១–ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាសលេខ [illegible] ពណ. បល. ប្រក

ស្តីពីការរៀបចំ និងការ[illegible]ត្តទៅរបស់នាយកដ្ឋានរដ្ឋបាល

* * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រឹតលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : នាយកដ្ឋានរដ្ឋបាល ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ ÷

-សំរបសំរួលរាល់កិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមចំណុះ ។

-គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។

-សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

-រៀបចំថវិកានៃទីស្តីការក្រសួង ។

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌក្នុងទីស្តីការក្រសួង ។

-ផ្គត់ផ្គង់ និងថែរក្សាសំភារៈការិយាល័យ ប្រេងឥន្ធនៈ គ្រឿងបន្លាស់ និងដោះស្រាយជីវភាពប្រាក់បៀវត្សដល់មន្ត្រីរាជការនៅទីស្តីការក្រសួង ។

-គ្រប់គ្រងបេឡា និងធ្វើរបាយការណ៍ចំណូល ចំណាយសាច់ប្រាក់ ។

ខ_ធ្វើរបាយការណ៍ចំណាយប្តរប្រទាន ។

ប្រការ ២ : នាយកដ្ឋានរដ្ឋបាល ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ។

ប្រការ ៣ : នាយកដ្ឋានរដ្ឋបាល មានការិយាល័យចំណុះចំនួន ០៥ គឺ :

១_ការិយាល័យរដ្ឋបាល និងការពារ

២_ការិយាល័យបូកសរុប

៣_ការិយាល័យទំនាក់ទំនងសាធារណៈ

៤_មជ្ឈមណ្ឌលតំកល់ឯកសារ «ថ្នាក់ស្មើការិយាល័យ»

៥_ការិយាល័យផ្គត់ផ្គង់

ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ។

ប្រការ ៤ : ការិយាល័យរដ្ឋបាល ទទួលបន្ទុក :

_សំរបសំរួលរាល់កិច្ចការរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមចំណុះក្រសួង ។

_គ្រប់គ្រង និងចរាចររាល់ឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

_ធានាសុវត្ថិភាព និងប្រសិទ្ធភាពរដ្ឋបាល ។

_គ្រប់គ្រង ថែរក្សា ការពារ និងប្រើប្រាស់អោយមានសុវត្ថិភាពនូវម៉ាស៊ីនថតចំលង កុំព្យូទ័រ ។

_ការងារការពារ សណ្តាប់ធ្នាប់ សន្តិសុខក្នុងទីស្តីការក្រសួង និងទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធលើការងារជំនាញ ។

ប្រការ ៥ : ការិយាល័យបូកសរុប ទទួលបន្ទុក :

_ពិនិត្យ និងផ្តល់យោបល់នូវរាល់លិខិតចេញ ចូលរបស់អគ្គនាយក អគ្គនាយករង ។

_ធ្វើកំណត់ហេតុប្រចាំសប្តាហ៍របស់ថ្នាក់ដឹកនាំក្រសួង ។

_ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ ដោយបូកសរុបសកម្មភាពការងាររបស់បណ្តាអង្គភាពក្រោមចំណុះក្រសួងជូនថ្នាក់ដឹកនាំពិនិត្យ ។

ប្រការ ៦ : ការិយាល័យទំនាក់ទំនងសាធារណៈ ទទួលបន្ទុក :

_ផ្តល់ និងទទួលពត៌មានជាសាធារណៈ រួមទាំងសំណូមពរផ្សេងៗ ។

–ផ្សព្វផ្សាយជូនសាធារណជន អំពីបណ្ដាវិធានការទាំងឡាយដែលក្រសួងពាណិជ្ជកម្មបានអនុវត្ត ។

–បង្កើតទំនាក់ទំនងជាសាធារណៈ រវាងប្រជាពលរដ្ឋ មន្ត្រីរាជការ និយោជិក និងអតិថិជនបរទេសនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណង :

+ការពារ ថែរក្សាផលប្រយោជន៍សាធារណៈ និងប្រយោជន៍ប្រជាពលរដ្ឋ

+ទំនាក់ទំនងពត៌មានផ្សេងៗ ក្នុងការប្រកបអាជីវកម្ម ពាណិជ្ជកម្ម សេវាកម្ម ។

+ទំនាក់ទំនងជាមួយបណ្ដាអង្គភាពពាក់ព័ន្ធ

អំពីពត៌មានស្ដីពីបណ្ដឹងតវ៉ានៃការរំលោភច្បាប់ រដ្ឋ ដែលទាក់ទងដល់វិស័យពាណិជ្ជកម្ម សេវាកម្ម ។

ប្រការ ៧ : មជ្ឈមណ្ឌលតំកល់ឯកសារ ទទួលបន្ទុក :

–តំកល់ គ្រប់គ្រង ថែរក្សាឯកសារដែលមានក្នុងប្រទេស និងពីជំនួយបរទេស ។

–បង្កលក្ខណៈងាយស្រួលជូនដល់មន្ត្រីរាជការ របស់ក្រសួងពាណិជ្ជកម្មចូលមកស្រាវជ្រាវ ដើម្បីបង្កើនន្ទូវចំណេះដឹង ។

–ប្រមូលសង្រួបដកស្រង់ខ្លឹមសារសំខាន់ៗពីឯកសារ ដែលពាក់ព័ន្ធផ្នែកពាណិជ្ជកម្មជូនថ្នាក់ដឹកនាំ ។

ប្រការ ៨ : ការិយាល័យផ្គត់ផ្គង់ ទទួលបន្ទុក :

–រៀបចំថវិកានៃទីស្ដីការក្រសួង ។

–គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌក្នុងទីស្ដីការក្រសួង ។

–ផ្គត់ផ្គង់ និងបែងចែក សំភារៈការិយាល័យ ប្រេងឥន្ធនៈ គ្រឿងបន្លាស់ និងដោះស្រាយជីវភាពប្រាក់បៀវត្សដល់មន្ត្រីរាជការនៅទីស្ដីការក្រសួង ។

–គ្រប់គ្រងបេឡា និងធ្វើរបាយការណ៍ចំណូល ចំណាយសាច់ប្រាក់ ។

–ធ្វើរបាយការណ៍ចំណាយបុរេប្រទាន ។

ប្រការ ៩ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១០: អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ នៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ១១ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហិរញ្ញវត្ថុ និងគ្រោ

ចម ប្រសិទ្ធ

* * * *

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៣៣៥ ពណ.បល.ប្រក

ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ

របស់នាយកដ្ឋានបុគ្គលិក

* * * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែសីហាឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ–បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

–យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : នាយកដ្ឋានបុគ្គលិក ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ :

–គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

–រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព ។

–ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។

–វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។

–រៀបចំនីយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។

–រៀបចំស្ថិតលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ ។

–គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

ប្រការ ២ : នាយកដ្ឋានបុគ្គលិក ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានបុគ្គលិក មានការិយាល័យចំណុះចំនួន ០៣ គឺ :

១–ការិយាល័យបុគ្គលិក

២–ការិយាល័យបៀវត្សរ៍វត្តកម្ម

៣–ការិយាល័យបណ្តុះបណ្តាលធនធានមនុស្ស

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ

ប្រការ ៤ : ការិយាល័យបុគ្គលិក ទទួលបន្ទុក :

- គ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការ ក្នុងការតំឡើងឋានៈ បន្ថយឋានៈនាទី សំរួលភារកិច្ច ផ្លាស់ បញ្ជូន ផ្អាកការងារ ដោយពុំទទួលប្រាក់បៀវត្សរ៍ ទូទាត់ណែនាំដើម្បីកែប្រែឡើងវិញ ការដាក់វិន័យ លុបឈ្មោះឬបណ្តេញចេញពីក្របខ័ណ្ឌរដ្ឋ ។
- ពិនិត្យ និងបញ្ជូនមន្ត្រីរាជការផ្នែកជំនាញ ដែលត្រូវទៅបំពេញទស្សនកិច្ចនៅបរទេស។
- គ្រប់គ្រងសំណុំឯកសារជីវប្រវត្តិមន្ត្រីរាជការ ។
- ការងារប័ណ្ណសំគាល់ខ្លួន ។
- រៀបចំ ឬកែសំរួលបទកំណត់នៃការរៀបចំ និងការប្រព្រឹត្តិទៅ និងលក្ខន្តិកៈការងាររបស់ក្រសួងពាណិជ្ជកម្ម បណ្តាអង្គភាពក្រោមចំណុះ និងបណ្តាញពាណិជ្ជកម្មខេត្ត-ក្រុង តាមសភាពការណ៍ គោលការណ៍ និងច្បាប់របស់រដ្ឋ ។
- ព្រាងសេចក្តីរាយការណ៍ សេចក្តីសំរេច ប្រកាសស្តីពីការបង្កើត ឬរំសាយអង្គការចាត់តាំង របស់បណ្តាអង្គភាពក្រោមចំណុះក្រសួងពាណិជ្ជកម្ម ។

ប្រការ ៥ : ការិយាល័យបៀវត្សរ៍ ពលកម្ម ទទួលបន្ទុក :

- គ្រប់គ្រងនិងបែងចែកក្របខ័ណ្ឌ ពលកម្ម តណាទានបៀវត្សរ៍មន្ត្រីរាជការរបស់ក្រសួង។
- ពិនិត្យ និងរៀបចំបទដ្ឋានបច្ចេកទេសពលកម្ម ការធានារ៉ាប់រងសង្គម ។
- ជ្រើសរើសបុគ្គលិកថ្មីដោយធ្វើការប្រឡងប្រជែងទៅតាមតំរូវការចាំបាច់របស់ក្រសួង ។
- តំលើងការបៀវត្សរ៍ប្រចាំឆ្នាំជូនមន្ត្រីរាជការរបស់ក្រសួង ។
- ដោះស្រាយប្រាក់ឧបត្ថម្ភចំពោះអ្នកដែលសុំលាលែងពីការងារ អ្នកដែលត្រូវបាត់បង់សមត្ថភាពពលកម្ម និងអ្នកដែលត្រូវចូលនិវត្តន៍ ។
- ពិនិត្យសភាពការណ៍ពលកម្ម ក្របខ័ណ្ឌប្រចាំខែ របស់បណ្តាអង្គភាព ក្រោមចំណុះក្រសួង ។
- ធ្វើស្ថិតិ និងធ្វើជំរឿនមន្ត្រីរាជការរបស់បណ្តាអង្គភាពក្រោមចំណុះក្រសួង ។
- ទទួលបែងចែកនិងរៀបចំភារងារចំពោះសិស្សនិស្សិតដែលរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈបញ្ជូនមក ។
- បូកសរុបប្រចាំឆ្នាំតណាទានបៀវត្សរ៍តណាទាននិវត្តជនបាត់បង់សមត្ថភាពពលកម្ម និងសង្គ្រោះសង្គម ។

ប្រការ ៦ : ការិយាល័យបណ្តុះបណ្តាលធនធានមនុស្ស ទទួលបន្ទុក ÷

- វាយតំលៃតំរូវការ និងធ្វើផែនការក្នុងការបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ។
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- ពិនិត្យ និងបញ្ជូនមន្ត្រីជំនាញ ដើម្បីចូលរួមសិក្ខាសាលា ឬត្រូវទៅបន្តការសិក្សា ទាំងរយៈពេលវែង ខ្លី នៅក្នុង និងក្រៅប្រទេស ។
- គ្រប់គ្រងវគ្គសិក្សាបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ។

ប្រការ ៧ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៨ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពអនុវត្តន៍ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៣៣៦ ពណ.បល.ប្រក
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
របស់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

* * * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងតាមការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ ÷

-លើកគំរោងថវិកាក្រសួង និងតាមដានវិលើកពីការប្រតិបត្តិ ។

-ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។

-ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា ។

-តាមដានវិលើកការគ្រប់គ្រងគណនីពិសេស ។

-ប្រមូលផ្តុំ និងសំរបសំរួលរាល់វិកាយរបស់ក្រសួង

-គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

-ប្រមូលផ្តុំតំរូវការធ្វើកម្មវិធីចំណាយ ការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់ក្រសួង

-គ្រប់គ្រងបញ្ជីចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។

-ធ្វើគំរោងកម្មវិធីចំណាយ បែងចែងប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។

-កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ ។

-ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

–ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

ប្រការ ២ : នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ មានការិយាល័យចំណុះចំនួន ០២ គឺ :

១_ការិយាល័យគណនេយ្យ

២_ការិយាល័យហិរញ្ញកិច្ច

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ។

ប្រការ ៤ : ការិយាល័យគណនេយ្យទទួលបន្ទុក ÷

–ផ្សព្វផ្សាយច្បាប់ អនុក្រឹត្យ សារាចរ សេចក្តីណែនាំពាក់ព័ន្ធនឹងការងារគណនេយ្យ ។

–ណែនាំការអនុវត្តន៍ការងារគណនេយ្យ ។

–ត្រួតពិនិត្យ និងគ្រប់គ្រងឯកសារអំពីរបាយការណ៍សារពើភ័ណ្ឌ ។

–បូកសរុបរបាយការណ៍ របាយការណ៍គណនេយ្យ ។

–ស្រាវជ្រាវសៀវភៅ និងឯកសារស្តីអំពីគណនេយ្យ ។

–សិក្សាឯកសារគណនេយ្យដែលរដ្ឋបាលប្រកាសផ្សាយរួចណែនាំបន្ត ។

ប្រការ ៥ : ការិយាល័យហិរញ្ញកិច្ចទទួលបន្ទុក :

–ណែនាំការកសាង និងបូកសរុបគំរោងចំណូល-ចំណាយថវិកា ។

–ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា បែងចែកថវិកាដល់អង្គភាពក្រោមចំណុះក្រសួង ។

–តាមដានការប្រើប្រាស់ថវិកា ។

–តាមដានការបង់ចំណូលថវិកា ។

–តាមដានវិលិកការគ្រប់គ្រងគណនីពិសេស ។

–ពង្រឹងមានវិទ្យាសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

–បូកសរុបរបាយការណ៍ស្តីអំពីការគ្រប់គ្រងចំណូល-ចំណាយថវិកាតាមមាត្រាកំណត់។

–ទទួល និងពិនិត្យសំណើពាក់ព័ន្ធនឹងថវិការដ្ឋ ។

–រៀបចំបែបបទ និងប្រមូលផ្តុំសំណើតាមនីតិវិធីលទ្ធកម្ម ។

- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។
- ពិនិត្យ និងលើកសំណើទាក់ទងអំពីការជួល លក់ ឬផ្ទេរអចលនទ្រព្យ ។
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ ។
- ធ្វើរបាយការណ៍ការងារលទ្ធកម្ម ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គនាយកនៃអគ្គនាយកដ្ឋាន និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស។ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៨ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * * * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៣៣៧ ពណ.បល.ប្រក

ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ

របស់នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

* * * * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

ទេស។

–បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

–យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ១ : នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ ÷

១៩៩៧

–កំណត់ និងបែងចែកប្រភេទទំនិញយុទ្ធសាស្ត្រ និងបន្ទាប់បន្សំ ។

–កសាង និងកំណត់តម្លៃទំនិញយុទ្ធសាស្ត្រ ។

–ក្តាប់ជាប់ និងធ្វើស្ថិតិនូវបរិមាណទំនិញចរាចរលក់ដុំ លក់រាយ នៅលើទីផ្សារក្នុងប្រទេស ។

–ក្តាប់ និងត្រួតពិនិត្យស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់ ដូចជា អង្ករ ប្រេងឥន្ធនៈ ។ល។

–សហការជាមួយផ្នែកកសិកម្ម ដើម្បីទទួលពត៌មាន និងក្តាប់នូវប្រភពទំនិញកសិកម្ម រុក្ខកម្ម ទាំងបរិមាណ និងគុណភាព ដើម្បីរកទីផ្សារលក់ ។

ងនាយក

–ក្តាប់តំរូវការរបស់ផ្នែកកសិកម្ម ដើម្បីជួយជំរុញអោយមានការនាំចូលនូវមធ្យោបាយ និងឧបករណ៍ផលិតកម្មសំរាប់បំរើអោយវិស័យនេះ ។

វតាំងរាជ

–សហការជាមួយផ្នែកឧស្សាហកម្ម សិប្បកម្ម ដើម្បីស្រាវជ្រាវក្តាប់នូវផលិតផលក្នុងប្រទេស ដោយផ្តល់ពត៌មានអោយការផលិតសមស្រប តាមស្តង់ដាដែលអាចលក់បាន លើទីផ្សារក្នុងស្រុក និងក្រៅស្រុក ។

-ទទួលពត៌មានអំពីសកម្មភាពពាណិជ្ជកម្មនៅតាមបណ្តាខេត្ត ក្រុង និងបូកសរុបរាយការណ៍ជូនក្រសួង ។

-លើកគំរោងនៃសេចក្តីត្រូវការរបស់ទីផ្សារក្នុងប្រទេស នូវបណ្តាមុខទំនិញសំខាន់ៗ និងចាំបាច់ ។

-លើកគំរោងផែនការនូវបរិមាណផលិតផលសំរាប់នាំចេញ នាំចូល ។

-ធ្វើគំរោងភាគកំរិត (Quota) ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

-សំរេងថ្លៃទំនិញសំខាន់ៗ និងចុះណែនាំអោយពាណិជ្ជករបិទផ្លាកតំលៃ ដើម្បីងាយស្រួលដល់អ្នកប្រើប្រាស់ ។

-ទ្រទ្រង់ថ្លៃទំនិញកសិផល សៀងដែលមានសារៈសំខាន់បំរើជីវភាពរបស់ប្រជារាស្ត្រ និងសេដ្ឋកិច្ចជាតិ ។

-ត្រួតពិនិត្យការផ្សាយពាណិជ្ជកម្ម និងការប្រកួតប្រជែង ។

ប្រការ ២ : នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស មានការិយាល័យចំណុះចំនួន ០៤ គឺ :

១-ការិយាល័យផែនការ ស្ថិតិ ពត៌មាន

២-ការិយាល័យផលិតផលកសិកម្ម និងឧស្សាហផលផលិតក្នុងស្រុក

៣-ការិយាល័យតំលៃ

៤-ការិយាល័យគ្រប់គ្រងអាជីវកម្ម សេវាកម្ម និងការប្រកួតប្រជែង

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ។

ប្រការ ៤ : ការិយាល័យផែនការ ស្ថិតិ ពត៌មាន ទទួលបន្ទុក :

-ទទួលពត៌មានអំពីសកម្មភាពពាណិជ្ជកម្មនៃខេត្ត ក្រុង និងបូកសរុបជូនក្រសួង ។

-លើកជាគំរោងនៃសេចក្តីត្រូវការទីផ្សារក្នុងប្រទេស នូវមុខទំនិញសំខាន់ចាំបាច់ ។

-ធ្វើស្ថិតិជូនក្រសួង អំពីសកម្មភាពពាណិជ្ជកម្មជាសៀវភៅប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ។

- លើកគំរោងផែនការមុខទំនិញជាយុទ្ធសាស្ត្រមួយចំនួនសំរាប់នាំចេញ នាំចូល ។
- លើកគំរោងភាគកំរិត (Quota) ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីងាយស្រួលផ្តល់អាជ្ញាប័ណ្ណ ។
- ផ្សព្វផ្សាយរាល់ពត៌មានពាណិជ្ជកម្ម តាមរយៈព្រឹត្តិប័ត្ររបស់ក្រសួង ។

ប្រការ ៥ : ការិយាល័យផលិតផលកសិកម្ម និងឧស្សាហផលផលិតក្នុងស្រុក ទទួលបន្ទុក :

- ក្តាប់រាល់គំរោងបរិមាណវត្ថុធាតុដើមសំរាប់ផលិតកម្ម ជៀសវាងការប្រើប្រាស់ខុសទិសដៅ ។
- ក្តាប់នូវបរិមាណទំនិញចរាចរលើផ្ទៃប្រទេស : ចរាចរលក់ដុំ រាយ នៅលើទីផ្សារ ដើម្បីផលប្រយោជន៍អ្នកប្រើប្រាស់ និងការពារជីវភាពរស់នៅរបស់ប្រជារាស្ត្រ ។
- ក្តាប់ស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់ដូចជា : ប្រេងឥន្ធនៈ ស្ករស ក្រណាត់ ទេសឯក គេតារ៉ុង សៀវភៅសរសេរ ក្រដាសសារពត៌មាន ។ល។
- ស្រង់ពត៌មានផ្សេងៗ នៅពេលទំនិញមកដល់មាត់ច្រកនាំចូល ។
- សហការជាមួយផ្នែកកសិកម្ម ឧស្សាហកម្ម ដើម្បីទទួលពត៌មាន និងក្តាប់នូវបរិមាណគុណភាពស្តង់ដាទំនិញ : ស្បៀង ពោត កសិផល កៅស៊ូ ឈើ រុក្ខផល ការចិញ្ចឹមសត្វ ។ល។ ដើម្បីរកទីផ្សារដាក់លក់ ។
- ត្រូវសហការ និងជំរុញអោយក្រុមហ៊ុនរដ្ឋ និងឯកជនធ្វើការនាំចូលនូវជី ឧបករណ៍កសិកម្ម ។ល។ ដើម្បីបំរើតំរូវការរបស់ប្រជាកសិករក្នុងផលិតកម្ម ។
- ទំនាក់ទំនង និងធ្វើជាអាជ្ញាកណ្តាលរវាងកសិករ និងពាណិជ្ជករ ដើម្បីរកទីផ្សារជូនកសិករ ។
- ទំនាក់ទំនង នឹងអង្គការអន្តរជាតិ ដើម្បីជួយដល់ផលិតកសិកម្មនូវពូជនានា ដែលអាចបានទទួលផលសមស្របតាមលក្ខណៈតំរូវការទីផ្សារក្នុង និងក្រៅប្រទេស ។
- លើកគំរោងនូវបរិមាណទឹកប្រាក់ ដើម្បីជួយដល់ផលិតករកសិកម្ម នូវមុខកសិផលដែលមានសារៈសំខាន់ក្នុងការនាំចេញដោយលើក Quota បេឡាទឹកប្រាក់សំរាប់ជួយកសិករ ។

- ការពារផលិតផលដំណាំកសិកម្ម ឬផលិតផលប្រហាក់ប្រហែលដែលអាចផលិតបាននៅក្នុងស្រុក ។ល។ រីឯការនាំចូលសំរាប់ជានាការផ្គត់ផ្គង់ជាវត្ថុធាតុដើម ត្រូវទទួលការអនុគ្រោះ ។
- សហការនឹងផ្នែករុក្ខាប្រមាញ់ ដើម្បីក្តាប់ពត៌មាននូវគំរោងបរិមាណព្រៃដែលត្រូវជានារក្សាទុក និងបរិមាណដែលអាចនាំចេញបាន ។
- ក្តាប់អនុផលព្រៃឈើដោយផ្តល់ពត៌មានទៅកាន់ទីផ្សារ ដើម្បីងាយស្រួលចរាចរលក់ទៅទីផ្សារក្នុង និងក្រៅប្រទេស ។

ប្រការ ៦ : ការិយាល័យតំលៃ ទទួលបន្ទុក :

- ចុះណែនាំអោយពាណិជ្ជករបិទស្លាកថ្លៃ ដើម្បីងាយស្រួលដល់អ្នកប្រើប្រាស់ និងជៀសវាងកេងប្រវ័ញ្ច របស់ពាណិជ្ជករលើអ្នកប្រើប្រាស់ ។
- ត្រួតពិនិត្យថ្លៃទំនិញទូទៅនៅលើទីផ្សារ និងតំលៃដែលរដ្ឋត្រូវគ្រប់គ្រងផ្តាច់មុខ ។
- កំណត់ថ្លៃទំនិញយុទ្ធសាស្រ្តសំខាន់ៗចាំបាច់ ដែលមានចែងក្នុងប្រកាសរបស់ក្រសួងដូចជា ស្បៀង ប្រេងឥន្ធនៈ ឱសថ ។ ល។ តាមរយៈការណែនាំពាណិជ្ជករ ឬអោយចេះធ្វើតារាងគណនាថ្លៃដើមលើទំនិញនាំចូល និងផលិតផលក្នុងប្រទេស(Decompte de prix) ។
- សិក្សថ្លៃទំនិញសំខាន់ៗសំរាប់ជីវភាពរស់នៅរបស់ប្រជារាស្រ្ត និងត្រូវមានវិធានការទប់ស្កាត់នៅពេលណាកើតមា[illegible]ថ្លៃ ។
- ទ្រទ្រង់ថ្លៃកសិផលដែលមា[illegible]សំខាន់បំរើជីវភាពរបស់ប្រជារាស្រ្ត និងសេដ្ឋកិច្ចជាតិ ដោយលើកជាវិធានការផ្សេងៗជូនរាជរដ្ឋាភិបាល ។
- ស្រង់តំលៃទំនិញសំខាន់ៗតាម[illegible]ព្រំដែន ។

ប្រការ ៧ : ការិយាល័យគ្រប់គ្រងអាជីវកម្ម សេវាកម្ម និងការប្រកួតប្រជែង ទទួលបន្ទុក :

- រៀបចំ គ្រប់គ្រងសកម្មភាពអាជីវកម្ម សេវាកម្មពាណិជ្ជកម្មក្នុងប្រទេស ។
- ត្រួតពិនិត្យការផ្សាយពាណិជ្ជកម្ម ក្នុងប្រទេសតាមរយៈការបិទផ្សាយ តាមរយៈសារពត៌មាន តាមរយៈវិទ្យុ និងទូរទស្សន៍ ។ ល ។
- រៀបចំសកម្មភាពប្រកួតប្រជែងអោយមានយុត្តិធម៌ ដើម្បីជៀសវាងការផ្តាច់មុខលើទីផ្សារ ។

-ជួយជំរុញនិងលើកទឹកចិត្តអោយបង្កើតជាសមាគមរបស់អាជីវករ តាមមុខរបរផ្សេងៗ។

ប្រការ ៨ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៩ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ នៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ១០ : ប្រកាសនេះមានអានុភាពអនុវត្តភ្លាម ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៣៨ ពណ.បល.ប្រក

ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ

របស់នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អន.ក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃ អគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ :

- កសាងគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ។
- ផ្តល់អាជ្ញាប័ណ្ណនាំចេញ នាំចូល ។
- ស្រាវជ្រាវទីផ្សារ និងថ្លៃទំនិញអន្តរជាតិ ។
- ស្រាវជ្រាវលទ្ធភាពនាំចេញ ។
- សិក្សាពីតំរូវការក្នុងប្រទេស ។
- ធ្វើស្ថិតិនាំចេញ នាំចូល ។
- ធ្វើកិច្ចព្រមព្រៀងទ្វេភាគី ។
- ផ្តល់ និងទទួលពត៌មានពីក្រៅ តាមរយៈស្ថានតំណាងពាណិជ្ជកម្ម ។
- រួមចំណែកគ្រប់គ្រងជំនួយបរទេស ។
- ធ្វើពិព័រណ៍ជាតិ និងអន្តរជាតិ ។
- ទាក់ទងជាមួយបរទេស និងអង្គការអន្តរជាតិ ។
- រៀបចំឯកសារ សំរាប់ថ្នាក់ដឹកនាំប្រជុំជាមួយអន្តរជាតិ ។
- រៀបចំបន្ទាត់នយោបាយ និងយុទ្ធវិធីពាណិជ្ជកម្មក្រៅប្រទេស ។
- ធ្វើសន្ទស្សន៍សេដ្ឋកិច្ច ។

ប្រការ ២ : នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស មានការិយាល័យចំណុះចំនួន ០៤ គឺ

១–ការិយាល័យនីហរ័ណ

២–ការិយាល័យអាហរ័ណ

៣–ការិយាល័យទាក់ទងបរទេស

៤–ការិយាល័យតម្លៃ និងស្រាវជ្រាវទីផ្សារអន្តរជាតិ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ ។

ប្រការ ៤ : ការិយាល័យនីហរ័ណ ទទួលបន្ទុក :

–ធ្វើបញ្ជីក្រុមហ៊ុននាំចេញ ។

–ផ្តល់អាជ្ញាប័ណ្ណនាំចេញទំនិញតាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម និងរាជរដ្ឋាភិបាល ។

–ផ្តល់វិញ្ញាបនបត្រទំនិញឆ្លងកាត់ ។

–ធ្វើស្ថិតិនាំចេញ

–ពិនិត្យល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ដែលមានតម្លៃទូទាត់សមស្រប ។

–ស្រាវជ្រាវតំរូវការក្រៅប្រទេស ។

–ស្រាវជ្រាវ និងផ្សព្វផ្សាយបែបបទបច្ចេកទេសពាណិជ្ជកម្មក្រៅប្រទេស ដើម្បីធ្វើអោយមានសុក្រឹតភាពក្នុងការនាំចេញទំនិញទៅបរទេស ។

–រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្មក្រៅប្រទេស ។

ប្រការ ៥ : ការិយាល័យអាហរ័ណ ទទួលបន្ទុក :

–ធ្វើបញ្ជីក្រុមហ៊ុននាំចូល ។

–ផ្តល់អាជ្ញាប័ណ្ណនាំចូលទំនិញតាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម និងរាជរដ្ឋាភិបាល ។

–ធ្វើស្ថិតិនាំចូល ។

–ពិនិត្យល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ដែលមានតម្លៃទូទាត់សមស្រប ។

–ស្រាវជ្រាវតំរូវការក្នុងប្រទេស ។

–ស្រាវជ្រាវ និងផ្សព្វផ្សាយបែបបទបច្ចេកទេសពាណិជ្ជកម្មក្រៅប្រទេស ដើម្បីធ្វើអោយមានសុក្រឹតភាពក្នុងការ នាំចូលទំនិញពីបរទេស ។

-រៀបចំគោលការណ៍នាំចូលទំនិញអោយមានលក្ខណៈសមហេតុសមផល ។

ប្រការ ៦ : ការិយាល័យទាក់ទងបរទេស ទទួលបន្ទុក :

-រៀបចំឯកសារជូនថ្នាក់ដឹកនាំប្រជុំជាមួយបរទេស ។

-រៀបចំកិច្ចព្រមព្រៀងទ្វេភាគី រវាងរាជរដ្ឋាភិបាលជាមួយនិងបរទេស ។

-តាមដានព័ត៌មានជាតិ និងអន្តរជាតិ ។

-រួមចំណែកទទួលជំនួយបរទេស ។

-ទំនាក់ទំនងនឹងស្ថានតំណាងពាណិជ្ជកម្មកម្ពុជាប្រចាំបរទេស និងក្តាប់ស្ថានភាពសេដ្ឋកិច្ច នៅបរទេសតាមរយៈ Internet

-ទំនាក់ទំនង និងរៀបចំការងារសហប្រតិបត្តិការទ្វេភាគីជាមួយបរទេស ។

ប្រការ ៧ : ការិយាល័យតម្លៃ និងស្រាវជ្រាវទីផ្សារអន្តរជាតិ ទទួលបន្ទុក :

-ស្រាវជ្រាវ និងតាមដានស្ថានភាពតម្លៃទំនិញលើទីផ្សារអន្តរជាតិ ។

-សិក្សាអំពីតំរូវការទីផ្សារអន្តរជាតិ ។

-រៀបចំ និងផ្សព្វផ្សាយតម្លៃទំនិញអន្តរជាតិតាមរយៈព្រឹត្តិបត្ររបស់ក្រសួង ។

ប្រការ ៨ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៩ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ១០ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

....

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩

ប្រកាស លេខ ៣៣៩ ពណ.ចល.ប្រក

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ

របស់នាយកដ្ឋាននីតិកម្ម

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនា រដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : នាយកដ្ឋាននីតិកម្ម ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានបរ ទេស មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ :

- តាក់តែងច្បាប់ពាណិជ្ជកម្ម ។

-កាន់កាប់បញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្មដូចមានចែងក្នុងច្បាប់ ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

-ស្រាវជ្រាវ ដកស្រង់ ចងក្រង អត្ថបទច្បាប់ពាណិជ្ជកម្ម និងសន្ធិសញ្ញាវិស័យពាណិជ្ជកម្ម និងគ្រប់គ្រងអត្ថបទច្បាប់ទាំងនោះ ។

-ណែនាំ តាមដានការអនុវត្តន៍ច្បាប់ពាណិជ្ជកម្ម និងសន្ធិសញ្ញាវិស័យពាណិជ្ជកម្ម ។

-ជាទីប្រឹក្សាច្បាប់ពាណិជ្ជកម្មដល់ថ្នាក់ដឹកនាំក្រសួង និងបណ្តាអង្គភាព ក្រុមហ៊ុន អាជីវកម្ម ពាណិជ្ជកម្ម ។

-ចូលរួមបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីនីតិកម្ម របស់ក្រសួងពាណិជ្ជកម្ម ។

ប្រការ ២ : នាយកដ្ឋាននីតិកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ។

ប្រការ ៣ : នាយកដ្ឋាននីតិកម្ម មានការិយាល័យចំណុះចំនួន ០២ គឺ

-ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម ។

២-ការិយាល័យច្បាប់ និងវិវាទពាណិជ្ជកម្ម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ។

ប្រការ ៤ : ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម ទទួលបន្ទុក :

-កាន់កាប់បញ្ជីពាណិជ្ជកម្ម ។

-ចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងសមាសភាពពាណិជ្ជកម្មដូចមានចែងក្នុងច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។

-ដោះស្រាយបញ្ហាដែលកើតមានឡើងពីការចុះបញ្ជីពាណិជ្ជកម្ម ។

ប្រការ ៥ : ការិយាល័យច្បាប់និងវិវាទពាណិជ្ជកម្ម ទទួលបន្ទុក

-តាក់តែងច្បាប់ពាណិជ្ជកម្ម ។

-ស្រាវជ្រាវ ដកស្រង់ ចងក្រងគ្រប់គ្រងអត្ថបទច្បាប់ពាណិជ្ជកម្ម និងសន្ធិសញ្ញាវិស័យពាណិជ្ជកម្ម ។

-ណែនាំ តាមដានការអនុវត្តន៍ច្បាប់ពាណិជ្ជកម្ម និងសន្ធិសញ្ញាវិស័យពាណិជ្ជកម្ម ។

-ជាទីប្រឹក្សាច្បាប់ពាណិជ្ជកម្មដល់ថ្នាក់ដឹកនាំក្រសួង និងបណ្តាអង្គភាព ក្រុមហ៊ុន អាជីវកម្ម ពាណិជ្ជកម្ម ។

-ចូលរួមបណ្តុះបណ្តាល បំពាក់បំប៉នមន្ត្រីនីតិកម្មរបស់ក្រសួង ។

-ដោះស្រាយ និងសំរុះសំរួលវិវាទពាណិជ្ជកម្មជាតិ និងអន្តរជាតិ ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៨ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

****

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ប្រកាស លេខ ៣៤០ ពណ.បល.ប្រក
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
របស់នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

****

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងតាមការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ :

-ផ្សព្វផ្សាយពត៌មាន ស្តីពីប្រព័ន្ធអនុគ្រោះទូទៅ (G S P) ដល់ពាណិជ្ជករ ផលិតករ មុខទំនិញនាំចេញទាំងឡាយ និងអោយគេចេះប្រើប្រាស់នូវប្រព័ន្ធនេះ ដើម្បីជាអត្ថប្រយោជន៍ ដល់ការជំរុញអាហារណកម្មទំនិញ ពីព្រះរាជាណាចក្រកម្ពុជា ។

-ពិនិត្យ និងចេញវិញ្ញាបនបត្រប្រភពដើមទំនិញអោយដល់ផលិតករ អ្នកវិនិយោគទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម មានការិយាល័យចំណុះចំនួន ០៣ គឺ

១-ការិយាល័យផ្សព្វផ្សាយពត៌មាន និងចុះបញ្ជី

២-ការិយាល័យអធិការកិច្ចបច្ចេកទេស

៣-ការិយាល័យចេញវិញ្ញាបនបត្រ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ។

ប្រការ ៤ : ការិយាល័យផ្សព្វផ្សាយពត៌មាន និងចុះបញ្ជី ទទួលបន្ទុក ÷

-ស្រាវជ្រាវអត្រាពន្ធនៃប្រទេសដែលផ្តល់ GSP និង MFN ដល់កម្ពុជា ។

ប្រការ

–ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ឆមាស ប្រាំបួនខែ និង ប្រចាំឆ្នាំ ។

–ចុះបញ្ជីក្រុមហ៊ុនទាំងឡាយដែលមានបំណងស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើម កំណើត ទំនិញ ។

–ទទួលពត៌មាននិងឯកសារនានាដែលទាក់ទងនឹងវិស័យនេះពីអន្តរជាតិ ជាពិសេស ពី United Nation Conference on Trade and Development (UNCTAD) នៅហ្សឺណែវ ។

–រៀបចំ និងចូលរួមសិក្ខាសាលានៅអន្តរជាតិ ។

–ផ្សព្វផ្សាយពត៌មានអំពីអត្ថប្រយោជន៍នៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី កាសែត ព្រឹត្តិបត្រ និងបើកសិក្ខាសាលានៅក្នុងស្រុក ឬតាម មធ្យោបាយផ្សេងៗ ។

–ណែនាំលើជំនាញបច្ចេកទេសដល់ពាណិជ្ជករ ផលិតករ ដើម្បីអោយទទួលបាន នូវការអនុគ្រោះ ។

–ផ្តល់ពត៌មានអំពីទំរង់បែបបទ នៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។

–ទំនាក់ទំនងក្នុងជាតិ អន្តរជាតិ ។

–បោះពុម្ពសៀវភៅតាមគំរោងរបស់ប្រទេសនីមួយៗ ។

–ធ្វើស្ថិតិអំពីកំណើនក្រុមហ៊ុនដែលធ្វើទំនាក់ទំនងនឹងនាយកដ្ឋានប្រព័ន្ធអនុគ្រោះ ពាណិជ្ជកម្ម ។

ប្រការ ៥ : ការិយាល័យអធិការកិច្ចបច្ចេកទេស ទទួលបន្ទុក ÷

–ផ្ទៀងផ្ទាត់ (Verification) ដើម្បីឆ្លើយតបអោយបានទាន់ពេលវេលាទៅប្រទេស ដែលផ្តល់ការអនុគ្រោះ GSP និង MFN ដល់កម្ពុជា ។

–ធ្វើការចរចាជាមួយបណ្តាប្រទេសផ្តល់ GSP ។

–ត្រួតពិនិត្យលើការប្រព្រឹត្តិមិនត្រឹមត្រូវ និងការក្លែងបន្លំ ។

–ពិនិត្យលើការស្នើសុំ OPA :(កិច្ចព្រមព្រៀងការកែច្នៃខាងក្រៅប្រទេស : Outward Processing Arrangement) ។

ប្រការ ៦ : ការិយាល័យចេញវិញ្ញាបនបត្រ ទទួលបន្ទុក ÷

–ចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញជាវាយនភណ្ឌ និងក្រៅពីវាយនភណ្ឌជូនដល់ផលិតករ ពាណិជ្ជករ និងអ្នកវិនិយោគទុន ។

–ធ្វើស្ថិតិនៃការនាំចេញវាយនភ័ណ្ឌ និងក្រៅពីវាយនភណ្ឌតាមប្រទេស និងតាមក្រុមហ៊ុន

–លើកគំរោងបែងចែក Quota អោយរោងចក្រកាត់ដេរ ។

ប្រការ ៧ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៨ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ប្រកាស លេខ ៣៤១ ពណ.បល.ប្រក
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
របស់នាយកដ្ឋាន កម្មសិទ្ធិបញ្ញា

* * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

–យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : នាយកដ្ឋានកម្មសិទ្ធិបញ្ញា ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ :

–ចងក្រងច្បាប់ និងបទបញ្ញត្តិដែលទាក់ទងដល់ពាណិជ្ជសញ្ញា ។

–រៀបចំឯកសារសំរាប់ថ្នាក់ដឹកនាំទៅប្រជុំនៅ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ។

–ធ្វើព្រឹត្តិបត្រពាណិជ្ជសញ្ញា ។

–រៀបចំបទបញ្ញត្តិ និងបែបបទស្តីពីការចុះបញ្ជីពាណិជ្ជសញ្ញា និងកាន់កាប់បញ្ជីពាណិជ្ជសញ្ញា ។

ប្រការ ២ : នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានកម្មសិទ្ធិបញ្ញា មានការិយាល័យចំណុះចំនួន ០២ គឺ ÷

១–ការិយាល័យចុះបញ្ជីពាណិជ្ជសញ្ញា

២–ការិយាល័យផ្សព្វផ្សាយពត៌មាន

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ។

ប្រការ ៤ : ការិយាល័យចុះបញ្ជីពាណិជ្ជសញ្ញា ទទួលបន្ទុក ៖

- ទទួលពាក្យសុំចុះបញ្ជីពាណិជ្ជសញ្ញា ។
- ពិនិត្យ និងធ្វើការផ្ទៀងផ្ទាត់ឯកសារផ្លាកសញ្ញា ។
- ចុះបញ្ជី និងផ្តល់វិញ្ញាបនបត្រ ។
- ធ្វើលិខិតឆ្លើយឆ្លងជាមួយអតិថិជនដែលទាក់ទងដល់ការចុះបញ្ជីពាណិជ្ជសញ្ញា ។
- ធ្វើស្ថិតិពាណិជ្ជសញ្ញា ។
- ដោះស្រាយបាតុភាពពីការចុះបញ្ជី ។
- រក្សាឯកសារចុះបញ្ជីពាណិជ្ជសញ្ញា ។

ប្រការ ៥ : ការិយាល័យផ្សព្វផ្សាយពត៌មាន ទទួលបន្ទុក ៖

- ចងក្រង និងធ្វើព្រឹត្តិបត្រពាណិជ្ជសញ្ញា ។
- ស្រាវជ្រាវ និងចងក្រងឯកសារពាណិជ្ជសញ្ញា ។
- ផ្សព្វផ្សាយច្បាប់ពាណិជ្ជសញ្ញា
- ទំនាក់ទំនងជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ។
- ទំនាក់ទំនងជាតិ និងអន្តរជាតិក្នុងក្រមខ័ណ្ឌការងារកម្មសិទ្ធិបញ្ញា ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៨ : ប្រកាសនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ប្រកាស លេខ ៣៩២ ពណ.បឈ.ប្រក

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ

របស់នាយកដ្ឋាន អាស៊ាន និងអង្គការអន្តរជាតិ

* * * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួល សមាភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ :

-វិភាគ គ្រប់គ្រងការងារអាស៊ាន ដែលទាក់ទិនផ្ទាល់និងសមត្ថកិច្ច របស់ក្រសួងពាណិជ្ជកម្ម ។

-ធ្វើការសំរបសំរួល និងទំនាក់ទំនងជាមួយស្ថាប័ននានា ពិសេសជាមួយអគ្គនាយកដ្ឋានអាស៊ាន របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងអង្គការតំបន់ពាណិជ្ជកម្មសេរីអាស៊ាន(AFTA) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-រួមចំណែករៀបចំមុខទំនិញសំរាប់បញ្ចូលក្នុងកម្មវិធីពន្ធគយអនុគ្រោះរួម (CEPTscheme សំរាប់) AFTA ។

-ចូលរួមរៀបចំគោលនយោបាយ និងយុទ្ធវិធីរបស់កម្ពុជា ក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ាន ។

-ធ្វើជាមជ្ឈមណ្ឌល នៃក្រុមការងារសំរបសំរួល ផ្នែកសេវាកម្មរបស់អាស៊ាន។

-ធ្វើការចរចាផ្នែកពាណិជ្ជកម្ម តាមកិច្ចព្រមព្រៀងជាទូទៅ ស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT)និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

-សហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ជាមួយអង្គការអន្តរជាតិនានាដូចជា: (APEC. ESCAP.WIPOEU.UNCTAD.UNCED) ។ល។

-ធ្វើការពិចារណា និងលើកផែនការជូនក្រសួង ដើម្បីទប់ទល់នឹងការធ្វើពាណិជ្ជកម្មមិនសមស្របតាមបទបញ្ញត្តិ អង្គការពាណិជ្ជកម្មពិភពលោក របស់ដៃគូពាណិជ្ជកម្ម ។

-ធ្វើការចរចាលើវិធានការនានាអំពីតារាងពន្ធ និងតារាងមិនមែនពន្ធ (Tariff and Non.Tariffmeasurcs) ។

-ធ្វើជាអ្នកសម្របសម្រួល អោយក្រសួងពាក់ព័ន្ធ ក្នុងការចរចាជាមួយអង្គការពាណិជ្ជកម្ម ពិភពលោក ក៏ដូចជាដោះស្រាយជំលោះពាណិជ្ជកម្មនានា ។

-ប្រមូលពត៌មានផ្នែកពាណិជ្ជកម្ម ។

-ផ្សព្វផ្សាយបទបញ្ញត្តិ និងកិច្ចព្រមព្រៀង ដែលកម្ពុជាត្រូវអនុវត្ត ។

ប្រការ ២ : នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ មានការិយាល័យចំណុះចំនួន ០៣ គឺ :

១-ការិយាល័យសំរបសំរួល និងអង្គការអន្តរជាតិ

២-ការិយាល័យអាស៊ាន

៣-ការិយាល័យអង្គការពាណិជ្ជកម្មពិភពលោក

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ។

ប្រការ ៤ : ការិយាល័យសំរបសំរួល និងអង្គការអន្តរជាតិ ទទួលបន្ទុក :

-សំរបសំរួលការងារជាមួយនាយកដ្ឋាននានាក្រោមចំណុះក្រសួងពាណិជ្ជកម្ម និងជាមួយក្រសួងពាក់ព័ន្ធ ។

-រៀបចំកិច្ចការទូទៅជូនថ្នាក់ដឹកនាំនាយកដ្ឋាន ។

-ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ ។

ប្រការ ៥ : ការិយាល័យអាស៊ាន ទទួលបន្ទុក :

-តាមដានការអនុវត្តន៍កម្មវិធីពន្ធគយអនុគ្រោះរួម(CEPT)និងអង្គការតំបន់ពាណិជ្ជកម្មសេរី អាស៊ាន(AFTA) ។

-អនុវត្តការងារអាស៊ាន និងសេវាកម្ម ។

-រៀបចំគោលនយោបាយអនុវត្តកិច្ចព្រមព្រៀងអាស៊ាន ។

-សិក្សាពីដៃគូពាណិជ្ជកម្មសំខាន់ៗរបស់អាស៊ាន ។

-ចូលរួមប្រជុំការងារអាស៊ាន ។

ប្រការ ៦ : ការិយាល័យអង្គការពាណិជ្ជកម្មពិភពលោក ទទួលបន្ទុក :

-ជាសេនាធិការដល់ក្រសួងពាណិជ្ជកម្មក្នុងការចរចាផ្នែកពាណិជ្ជកម្មកិច្ចព្រមព្រៀងជាទូទៅ ស្តីពីពន្ធគយនិងពាណិជ្ជកម្ម(GATT) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ព្រមទាំងវិធានការនានាអំពីតារាងពន្ធ និងតារាងមិនមែនពន្ធ (Tariff and Non.Tariff measures) ។

-ធ្វើការពិចារណា និងលើកផែនការជូនក្រសួង ដើម្បីទប់ទល់នឹងការធ្វើពាណិជ្ជកម្មមិនសមស្របតាមបទបញ្ញត្តិអង្គការពាណិជ្ជកម្មពិភពលោក របស់ដៃគូពាណិជ្ជកម្ម ។

-ធ្វើជាអ្នកសម្របសម្រួល និងចូលរួមជាមួយក្រសួងពាក់ព័ន្ធ ក្នុងការចរចាជាមួយអង្គការពាណិជ្ជកម្មពិភពលោក ក៏ដូចជាដោះស្រាយជំលោះពាណិជ្ជកម្មនានា ។

-ប្រមូលពត៌មានផ្នែកពាណិជ្ជកម្មអន្តរជាតិ ។

–ផ្សព្វផ្សាយបទបញ្ញត្តិ និងកិច្ចព្រមព្រៀងដែលកម្ពុជាត្រូវអនុវត្ត ។

–ធ្វើទំនាក់ទំនងជាមួយតំណាងនៅ WTO ។

ប្រការ ៧ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៨ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

****

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ប្រកាស លេខ ៣៤៣ ពណ.បល.ប្រក
ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ
របស់នាយកដ្ឋាន ជំរុញការនាំចេញ

* * * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

–បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ :នាយកដ្ឋានជំរុញនាំចេញ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់នៃអគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីភារកិច្ចដូចតទៅ ÷

-រៀបចំគំរោង និងដឹកនាំផែនការប្រតិបត្តិ ដើម្បីជំរុញលើកកំពស់ពង្រីក និងបង្កើនសមត្ថភាពដល់ការនាំចេញនូវសំភារៈ ព្រមទាំងសេវាកម្ម និងពិភាក្សាយ៉ាងជិតស្និទ្ធជាមួយផលិតករដែលពាក់ព័ន្ធក្នុងការនាំចេញ ។

-ស្នើឡើងដល់បណ្តាក្រសួងដែលពាក់ព័ន្ធ នូវវិធានការទទួលខុសត្រូវក្នុងការជំរុញ និងបង្កលក្ខណៈងាយស្រួលដល់ការនាំចេញ ផលិតផលក្នុងស្រុក ។

-គាំទ្រគំរង់ និងលើកទឹកចិត្តការចូលរួមរបស់ផលិតករជាតិ នៅក្នុងពិធីតាំងបង្ហាញទំនិញ និងពិព័រណ៍ជាតិ ព្រមទាំងអន្តរជាតិ ។

-ចូលរួមនៅក្នុងការបង្កើតឡើងនូវបែបបទធ្វើហិរញ្ញប្បទាននិងកិច្ចធានាដល់ការនាំចេញ

-ជួយដល់អ្នកនាំចេញក្នុងការស្វែងរកទីផ្សារក្រៅប្រទេស និងសហការដល់រាល់កិច្ចការជំរុញការនាំចេញ ។

-ផ្តល់ព័ត៌មាន និងរៀបចំឯកសារដែលទាក់ទងទៅនឹងការពង្រីកខាងវិស័យពាណិជ្ជកម្ម និងឈានទៅដល់ការវិភាគ និងផ្សាយចេញនូវពត៌មានទាំងនោះផង ។

ប្រការ ២ : នាយកដ្ឋានជំរុញនាំចេញ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ ។

ប្រការ ៣ : នាយកដ្ឋានជំរុញនាំចេញ មានការិយាល័យចំណុះចំនួន ០២ គឺ :

១_ការិយាល័យបច្ចេកទេស និងប្រតិបត្តិ

២_ការិយាល័យពត៌មាន និងផ្សព្វផ្សាយ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានជាជំនួយការ

ប្រការ ៤ : ការិយាល័យបច្ចេកទេស និងប្រតិបត្តិ ទទួលបន្ទុក :

–សិក្សាពី MARKETING ។

–ទំនាក់ទំនងសាធារណៈ និងគ្រប់គ្រងឯកសារ សិក្ខាសារបស់នាយកដ្ឋាន ។

–រៀបចំ និងចូលរួមតាំងពិព័រណ៍ជាតិ និងអន្តរជាតិ ។

–គ្រប់គ្រងមជ្ឈមណ្ឌលពិព័រណ៍ ។

ប្រការ ៥ : ការិយាល័យពត៌មាន និងផ្សព្វផ្សាយ ទទួលបន្ទុក :

–ការងារច្បាប់ និងគោលនយោបាយ ។

–ស្រាវជ្រាវពត៌មានពាណិជ្ជកម្ម និងផ្សព្វផ្សាយឯកសារពាក់ព័ន្ធដល់ការនាំចេញ និង ទីផ្សារក្រៅប្រទេស ។

–បង្កើនការយល់ដឹង និងជំរុញការងារនាំចេញអោយកាន់តែប្រសើរឡើង ។

ប្រការ ៧ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៨ : អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

****

ខ_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ប្រកាសលេខ ៧៩១ អយក. ប្រក

ស្តីពីការអនុញ្ញាតអោយបើកសាលាឯកជន

ខ្មែរ_វៀតណាម គិង_គៀន

****

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_៩៤ ។
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ សន/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦_៧_៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញព្រះរាជក្រមលេខ សន/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤_០១_៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥_៦_៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន ។

_បានឃើញពាក្យស្នើសុំរបស់លោក ង្វៀង ង៉ុកសាន់ ចុះថ្ងៃទី ១០_១០_៩៣ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ចុះថ្ងៃទី ២៦_៧_៩៤

_តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក ង្វៀង ង៉ុកសាន់ បើកសាលាបឋមសិក្សាឯកជន ខ្មែរ_វៀតណាម ដែលមានទីតាំងនៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ១៩៩៧_៩៨ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សាឯកជនខ្មែរ_វៀតណាម គីង តៀន ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជននិងកីឡា រាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាត របស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៣ : លោក ង្វៀង ង៉ុកសាន់ ត្រូវដឹកនាំ គ្រប់គ្រង ចាត់តាំងគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ព្រមទាំងអនុវត្តអោយបានត្រឹមត្រូវ តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៤ : ប្រធានមន្ទីរក្រសួងអប់រំ យុវជន និងកីឡា លោកប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា លោកប្រធាននាយកដ្ឋានចាត់តាំង លោកប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ លោកប្រធានការិយាល័យអប់រំ យុវជននិងកីឡា ខណ្ឌ ៧មករា នាយកសាលាបឋមសិក្សាឯកជនខ្មែរ-វៀតណាម គីង តៀន និងលោក ង្វៀង ង៉ុកសាន់ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាអាន

* * * *

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី

លើកទី១ ចំនួន ៤០០ ច្បាប់

តម្លៃ ២៧៥០ រៀល